គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ
បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា
Regulate, Supervise, and Develop Trust Sector
in the Kingdom of Cambodia
និយ័តករបរធនបាលកិច្ច
Trust Regulator
លេខ៥៤ ចេញផ្សាយថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២២
No. 54 Released on September 13, 2022
អត្ថបទប្រចាំសប្តាហ៍ | Weekly Article

# ប្រតិបត្តិការបរធនបាលកិច្ចរបស់បរធនបាលរូបវន្តបុគ្គល

## Trust Operation of Physical Trustee



www.bing.com/images/search?view=detailV2&ccid=0GipJclq&id

យោងតាមច្បាប់ស្តីពី “បរធនបាលកិច្ច” (២០១៩), បទប្បញ្ញត្តិពាក់ព័ន្ធ និងប្រកាសលេខ ០០៣/អ.ស.ហ./ប្រក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២ ស្តីពី “វិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច” បរធនបាលរូបវន្តបុគ្គលដែលទទួលបានអាជ្ញាបណ្ណពីនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អាចធ្វើប្រតិបត្តិការ ដូចខាងក្រោម÷

**ក.** បរធនបាលរូបវន្តបុគ្គលនៃក្រុមហ៊ុនបរធនបាល អាចធ្វើប្រតិបត្តិការ÷

- ធ្វើសកម្មភាពតាមការណែនាំរបស់ក្រុមហ៊ុនបរធនបាលពាក់ព័ន្ធនឹងប្រតិបត្តិការបរធនបាលកិច្ច ដូចមានចែងក្នុងប្រការ ១៤ នៃប្រកាសស្តីពី “វិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច” ព្រមទាំងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ
- ធ្វើជាតំណាងក្រុមហ៊ុនបរធនបាល ស្របតាមការចាត់តាំងរបស់ក្រុមហ៊ុនបរធនបាល
- ធ្វើប្រតិបត្តិការ ឬសកម្មភាពផ្សេងទៀត ដែលអនុញ្ញាតដោយ **ន.ប.ធ.**។

**ខ.** បរធនបាលរូបវន្តបុគ្គលឯករាជ្យអាចធ្វើប្រតិបត្តិការបរធនបាលកិច្ច÷

- ធ្វើប្រតិបត្តិការបរធនបាលកិច្ច មួយឬច្រើនដូចជា÷ ប្រតិបត្តិការបរធនបាលកិច្ចសាធារណៈ, ប្រតិបត្តិការបរធនបាលកិច្ចហិរញ្ញវត្ថុ, ប្រតិបត្តិការបរធនបាលកិច្ចពាណិជ្ជកម្ម, ប្រតិបត្តិការបរធនបាលកិច្ចសង្គម, ប្រតិបត្តិការបរធនបាលកិច្ច

ប្រកាសបដិសេធ÷ ទស្សនៈនៅក្នុងអត្ថបទនេះជាទស្សនៈរបស់អ្នកនិពន្ធ។ ទស្សនៈនៅក្នុងអត្ថបទនេះមិនមែនជាទស្សនៈរបស់និយ័តករបរធនបាលកិច្ចទេ។
Disclaimer: The opinions expressed in this article are those of the authors. They do not purport to reflect the opinions or views of the Trust Regulator.

បុគ្គល និងប្រតិបត្តិការបរធនបាលកិច្ចផ្សេងទៀតតាមការកំណត់របស់ **ន.ប.ធ.** ព្រមទាំងទទួលបានអាជ្ញាបណ្ណ និង/ឬការអនុញ្ញាត អាចធ្វើជាប្រតិបត្តិការបរធនបាលកិច្ចដូចខាងក្រោម÷

- ជាជំនួយដល់បរធនបាលទាយក/អ្នកផ្តល់វិភាគទានបរធនបាលកិច្ច ក្នុងការដាក់ពាក្យស្នើសុំបង្កើតបរធនបាលកិច្ចដំបូង
- ចុះបញ្ជីបរធនបាលកិច្ច តាមលក្ខខណ្ឌច្បាប់ និងបទប្បញ្ញត្តិជាធរមានក្នុងវិស័យបរធនបាលកិច្ច
- គ្រប់គ្រង ចាត់ចែង និងថែរក្សាទ្រព្យសម្បត្តិបរធនបាលកិច្ច សម្រាប់ជាប្រយោជន៍ដល់អត្ថគាហកៈ ឬក្នុងគោលបំណងដែលត្រូវបានអនុញ្ញាតដោយ **ន.ប.ធ.**
- ថែរក្សាសុវត្ថិភាពសាច់ប្រាក់ ឬបរធន ដែលបរធនបាលទាយក/អ្នកផ្តល់វិភាគទានបរធនបាលកិច្ច បានផ្ទេរចូលបរធនបាលកិច្ច តាមរបៀបដូចមានចែងក្នុងលិខិតបរធនបាលកិច្ច ឬបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច
- កាន់កាប់បរធន/ទ្រព្យសម្បត្តិបរធនបាលកិច្ច ដោយអនុលោមតាមលិខិតបរធនបាលកិច្ច និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច
- ធ្វើជាតំណាងនៃភាពជាម្ចាស់កម្មសិទ្ធិស្របច្បាប់លើទ្រព្យសម្បត្តិបរធនបាលកិច្ច
- ទូទាត់ភាគលាភ ការប្រាក់ ឬលាភការផ្សេងៗ ដែលកើតចេញពីទ្រព្យសម្បត្តិបរធនបាលកិច្ច ដោយអនុលោមតាមលិខិតបរធនបាលកិច្ច និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច
- ត្រួតពិនិត្យសេចក្តីណែនាំផ្សេងៗពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិបរធនបាលកិច្ច និងការអនុវត្តផែនការសកម្មភាព ឬគម្រោងពាក់ព័ន្ធនឹងការចាត់ចែងបរធន និងកម្មីផ្សេងៗ ដែលត្រូវបានអនុញ្ញាតដូចក្នុងកម្មវត្ថុនៃលិខិតបរធនបាលកិច្ច ត្រូវបានអនុវត្តត្រឹមត្រូវ
- ត្រួតពិនិត្យ និងតាមដានយ៉ាងសកម្ម ព្រមទាំងធានាថា ប្រតិបត្តិការ និងការគ្រប់គ្រងគម្រោងផែនការ និងការទូទាត់ចំណូលទទួលបាន ធ្វើឡើងដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន

- ធ្វើប្រតិបត្តិការ ឬសកម្មភាពផ្សេងទៀត ដែលអនុញ្ញាតដោយ **ន.ប.ធ.**។

ប្រកាសបដិសេធ÷ ទស្សនៈនៅក្នុងអត្ថបទនេះជាទស្សនៈរបស់អ្នកនិពន្ធ។ ទស្សនៈនៅក្នុងអត្ថបទនេះមិនមែនជាទស្សនៈរបស់និយ័តករបរធនបាលកិច្ចទេ។
Disclaimer: The opinions expressed in this article are those of the authors. They do not purport to reflect the opinions or views of the Trust Regulator.